ការបូជាព្រះធម៌
សូធ្យប្រចាំថ្ងៃ

រៀបរៀងដោយ

ធម្មានន្ទ ភ័ន់ ចាន់សាវ៉ែន

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
ព.ស.២៥៥៧

ឆ្នាំ ២០១៣

ការប្រចេះធម៌

សូធ្យប្រចាំថ្ងៃ

រៀបរៀងដោយ

មហាធម្មតណ្ហាគារិក: ខ្ញ ុ ំ ចាន់សារ៉ែន

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ព.ស.២៥៥៨

គ.ស.២០១៤

ឈ្មោះសៀវភៅ	*កម្រងព្រះធម៌ សូធ្យប្រចាំថ្ងៃ*
រៀបរៀងដោយ	*មហាធម្មកណ្ឌាគារិក: រ៉ាន់ ចាន់សារ៉ែន (ធម្មានន្ទ)*
កាលបរិច្ឆេទ	*ថ្ងៃ សៅរ៍ ៨ កើត ខែ មិគសិរ ឆ្នាំ មមី ឆស័ក ច.ស.១៣៧៦ ត្រូវនឹងថ្ងៃទី ២៩ ខែ វិច្ឆិកា ព.ស.២៥៥៨*
ចំនួនបោះពុម្ព	*១.៥០០ ក្បាល*
បោះពុម្ព	*ចែកជាធម្មទានក្នុងពិធីបុណ្យសាងព្រះត្រៃបិដក ២ ចប់ គម្ពីរអដ្ឋកថា ២ ចប់ ទូដាក់សៀវភៅ ២ ពិធីបុណ្យបច្ច័យបួន និងចម្រើនជន្មាយុ ជូនចំពោះឧបាសក* **តុង សាម** *ចំនួន ៧០០ ក្បាល*
បោះពុម្ព	*ចែកជាធម្មទានក្នុងពិធីបុណ្យលោកយាយឧបាសិកា* **ង៉ូ ឆ គី** *ចំនួន ៣០០ ក្បាល*

សម្ពោធនីយកថា

សៀវភៅធម៌ដែលមានចំណងជើងថា **ការប្រចាំថ្ងៃ សូធ្យប្រចាំថ្ងៃ** *នេះ ត្រូវ*
បានបោះពុម្ពចែកជាធម្មទានក្នុងពិធីបុណ្យសាងព្រះត្រៃបិដក ២ ចប់ គម្ពីរអដ្ឋកថា ២
ចប់ ទូដាក់សៀវភៅ ២ ពិធីបុណ្យបច្ច័យបួន និងពិធីបុណ្យចម្រើនជន្មាយុ ជូន
ចំពោះឧបាសក **គុង សាម** *ដែលត្រូវជាលោកឪពុក ជាជីតារបស់ម្ចាស់ធម្មទាន ដែល*
កំពុងមានជន្មាយុរស់នៅសព្វថ្ងៃនេះ និងដើម្បីបានឧទ្ទិសបុណ្យកុសលជូនចំពោះលោក
យាយឧបាសិកា **សៀក ឆេង** *និងជីដូន ជីតា ម៉ា កុង ដែលបានចែកស្ថានទៅកាន់លោក*
ខាងមុខ ដើម្បីទទួលអនុមោទនានូវបុណ្យកុសលនេះ ។ កម្មវិធីបុណ្យនេះ ប្រារព្ធធ្វើនៅ
ថ្ងៃសៅរ៍ ៨ កើត ខែ មិគសិរ ឆ្នាំ មមី ឆស័ក ច.ស.១៣៧៦ ត្រូវនឹងថ្ងៃទី ២៨ ខែ វិច្ឆិកា
ព.ស.២៥៥៨ ។

ម្ចាស់ធម្មទាន

-*លោកស្រី* **សាម យ៉ិនស៊ីម** *និងលោក* **ឌួន ប៉ែងស្រេង** *ព្រមទាំងបុត្រធីតា*
-*លោក* **សាម ចន់** *លោកស្រី* **ការ៉ង ប៉ុណ្ណា** *ព្រមទាំងបុត្រធីតា*
-*ឧបាសិកា* **សាម យ៉ែកឡាង** *និងឧបាសក* **គឹម ប៉ោស៊ីម** *ព្រមទាំងបុត្រធីតា*
-*លោក* **សាម ម៉ុងសេង** *និងលោកស្រី* **ជា គឹមម៉ុំ** *ព្រមទាំងបុត្រធីតា*
-*លោក* **សាម ហ៊ុកសេង** *និងលោកស្រី* **ទិន សុផា** *ព្រមទាំងបុត្រធីតា*
-*លោកស្រី* **សាម យ៉ែកណាង** *និងលោក* **គា ធី** *ព្រមទាំងបុត្រធីតា*
-*លោក* **សាម អេង** *និងលោកស្រី* **ទូច សុហៀប** *ព្រមទាំងបុត្រធីតា*
-*លោក* **សាម ឃុន** *និងលោកស្រី* **ឡេ សួយអ៊ី** *ព្រមទាំងបុត្រធីតា*
-*លោក* **សាម ឃន់** *និងលោកស្រី* **ស្រ៊ាង គឹមហាក់** *ព្រមទាំងបុត្រធីតា*
-*លោកស្រី* **សេង ឆួចអេង** *ព្រមទាំងបុត្រធីតា*

ឥមិនា ធម្មទានេន *ដោយអានុភាពនៃធម្មទាននិងបុណ្យកុសលទាំងអស់នេះ*
សូមលោកឧបាសក **គុង សាម** *ជួបប្រសព្ធនូវសេចក្ដីសុខ ប្រាសចាកទុក្ខសោក រោគភ័យ*
បរិបូណ៌ដោយ អាយុ វណ្ណ: សុខ: ពល: កុំបីឃ្លៀងឃ្លាតឡើយ ។

សម្មោទនីយកថា

សៀវភៅធម៌ដែលមានចំណងជើងថា **ក្រមួចព្រះធម៌ សូធ្យប្រចាំថ្ងៃ** *នេះ ត្រូវបានបោះពុម្ពចែកជាធម្មទានចំនួន ៣០០ ក្បាល ក្នុងពិធីបុណ្យបច្ច័យបួន និងពិធីបុណ្យចម្រើនជន្មាយុ ជូនចំពោះឧបាសិកា* **ង៉ូវ គី** *ដែលត្រូវជាអ្នកម្តាយ ជាជីដូន ដែលកំពុងមានជន្មាយុរស់នៅសព្វថ្ងៃនេះ និងដើម្បីបានឧទ្ទិសបុណ្យកុសលចំពោះបុព្វការីជន មានជីដូន ជីតា ម៉ា កុង ដែលបានចែកស្ពានទៅកាន់លោកខាងមុខ ដើម្បីទទួលអនុមោទនានូវបុណ្យកុសលនេះ។*

ម្ចាស់ធម្មទាន

-លោក **ស្រ៊ឿ ស្រ៊ាង** *អ្នកស្រី* **គា ម៉ាញ់** *ព្រមទាំងបុត្រធីតា*

ឥមិនា ធម្មទានេន *ដោយអានុភាពនៃធម្មទាននិងបុណ្យកុសលទាំងអស់នេះ សូមឧបាសិកា* **ង៉ូវ គី** *ជួបប្រសព្វនូវសេចក្តីសុខ ប្រាសចាកទុក្ខសោក រោគភ័យ បរិបូណ៌ដោយ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។*

បុព្វកថា

*កម្រងព្រះធម៌នេះ ខ្ញុំព្រះករុណា ខ្ញុំបានចងក្រងទុកសម្រាប់ធ្វើវត្ត សម្រាប់សូធ្យ ព្រឹក-ល្ងាច ជាបទនមស្ការសរសើរគុណព្រះរតនត្រ័យ និងផ្សាយនូវមេត្តាចិត្ត ចំពោះ សព្វសត្ត ។ ធម៌ទាំងនោះ មាន***ធម៌នមស្ការចំពោះព្រះរតនត្រ័យ បទអាការវត្តា, កំពូលកណ្ឌព្រះត្រៃបិដក, ការណបរិត្ត, អសីតិមហាសាវ័ក, ជីវទានគាថា:, មហាមេត្តាគាថា: (ធម៌មហាមេត្រី) មេត្តាសូត្រ និង ឲ្ជាន្ទសូត្រ** *ជាដើម ។ ធម៌ទាំងនេះ ជាធម៌ដែលបោរាណាចារ្យទាំងឡាយធ្លាប់សូធ្យបជិបត្តិមក ដូចជា* **ធម៌ជីវទាន, ធម៌មហាមេត្រី** *មានកាពល្ប៉ីរន្ទ្ធីថា មានអានុភាពស័ក្តិសិទ្ធិអាចជាសះស្បើយពីជំងឺផ្សេងៗ និងជាធម៌ផ្សាយមេត្តាដល់សព្វសត្ត ។ តែធម៌នេះ មិនមានជាទូទៅនោះទេ ហើយមិនធ្លាប់ឃើញព្រះថេរ: ឬអស់លោកណាប្រែជាកាសាសម្រាយទាល់តែសោះ ទើបខ្ញុំ ព្រះករុណា ខ្ញុំបានសាកល្បងត្រួតជម្រះកាសាបាលី រួមទាំងប្រែជាកាសាខ្មែរសម្រាយ ទុកជាគោលសូធ្យប្រចាំថ្ងៃរបស់ខ្លួន ។ ឯធម៌បទសូធ្យដទៃទៀត សុទ្ធតែជាបទពណ៌នា សរសើរគុណព្រះរតនត្រ័យ ដែលមានអត្ថន័យជ្រាលជ្រៅគួរឲ្យជ្រះថ្លា ដែលខ្លួន ខ្ញុំព្រះករុណា ខ្ញុំជាអ្នកពេញចិត្តយ៉ាងខ្លាំង ក្នុងការសូធ្យចម្រើនការនាព្រះពុទ្ធគុណ ព្រះធម្មគុណ និងព្រះសង្ឆគុណជាប្រចាំ ។ ហេតុដូច្នោះ ទើបប្រមូលជាកម្រងព្រះធម៌ មួយ សម្រាប់ខ្លួនឯង ដោយសន្ទតឈ្មោះថា កម្រងព្រះធម៌សូធ្យប្រចាំថ្ងៃ។*

នៅក្នុងខុទ្ទកនិកាយ ធម្មបទគាថា បិដកលេខ ៥២ ទំព័រ ៤៥ ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ថា

យំ កិញ្ចិ យិដ្ឋំ ៖ ហុតំ ៖ លោកេ
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ
សព្វម្ឪ តំ ន ចតុភាគមេតិ
អភិវាទនា ឧជ្ជុគតេសុ សេយ្យោ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជា

ធំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង
រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ ចំពោះលោក
ទាំងឡាយ ដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង ។

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ។

ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចំរើនដល់អ្នក
ដែលមានសេចក្ដីវិនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្ដីកោតក្រែង
ដល់បុគ្គលដែលចំរើនជាងខ្លួន អស់កាលជានិច្ច ។

អានិសង្សចម្រើនពុទ្ធានុស្សតិ

(ក្នុងគម្ពីរវិសុទ្ធិមគ្គ)

១.សត្ថរិ សការោ ហោតិ សប្ឋតិសេ្ឋ ជាអ្នកមានសេចក្ដីគោរព
មានសេចក្ដីកោតក្រែងចំពោះព្រះសាស្តា

២.សទ្ធាវេបុល្លំ រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌ដោយសទ្ធា

៣.សតិវេបុល្លំ រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌ដោយសតិ

៤.បញ្ញាវេបុល្លំ រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌ដោយបញ្ញា

៥.បុញ្ញវេបុល្លញ្ច អធិគច្ឆតិ រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌
ដោយបុណ្យកុសល

៦.បីតិចាមោជ្ជពហុលោ ហោតិ ជាអ្នកច្រើនទៅដោយបីតិ និងបាមោជ្ជ:

៧.ភយភេរវសហោ ទុក្ខាធិវាសនសមត្ថោ អត់ធន់ចំពោះភ័យ និងហេតុ
ដែលគួរឲ្យខ្លាច ជាអ្នកអាចអត់សង្កត់សេចក្ដីទុក្ខ

៨.សត្ថារា សំវាសសញ្ញំ បដិលភតិ *រមែងបានចំពោះនូវសេចក្តីសម្គាល់ថា ដូចជាបាននៅរួមជាមួយព្រះសាស្តា*

៩.ពុទ្ធគុណានុស្សតិយា អជ្ឈាវុត្ថញ្ចស្ស សរីរម្បិ ចេតិយឃរមិវ បូជារហំ ហោតិ *សូម្បីសរីរៈរបស់បុគ្គលនោះ ដែលការរលឹករឿយៗ នូវគុណព្រះពុទ្ធគ្រប់គ្រងហើយ ជាកាយគួរដល់ការបូជា ដូចជាផ្ទះនៃចេតិយ*

១០.ពុទ្ធភូមិយំ ចិត្តំ នមតិ *ចិត្តរមែងបង្អោនទៅក្នុងពុទ្ធភូមិ*

១១.វីតិក្កមិតព្វវត្ថុសមាយោគេ ចស្ស សម្មុខា សត្ថារំ បស្សតោ វិយ ហិរោត្តប្បំ បច្ចុបដ្ឋាតិ *មួយវិញទៀត កាលបើមានការជួបប្រសប់ នឹងវត្ថុដែលគួរប្រព្រឹត្តល្មើស ហិរិនិងឱតប្បៈ រមែងប្រាកដដល់បុគ្គលនោះ នៅចំពោះមុខ*

១២.ឧត្តរិ អប្បដិវិជ្ឈន្តោ បន សុគតិបរាយនោ ហោតិ *កាលមិនទាន់ចាក់ធ្លុះនូវគុណធម៌ខ្ពង់ខ្ពស់ រមែងជាអ្នកមានសុគតិទៅខាងមុខ ។*

តស្មា ហវេ អប្បមាទំ កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ ពុទ្ធានុស្សតិយា សទា។

ព្រោះហេតុនោះឯង អ្នកមានបញ្ញាល្អ គប្បីធ្វើសេចក្តីមិនប្រមាទ
ក្នុងពុទ្ធានុស្សតិ ដែលមានអានុភាពច្រើន យ៉ាងនេះ គ្រប់ៗកាល ។

ថ្ងៃសៅរ៍ ៨ កើត ខែ មិគសិរ ឆ្នាំ មមី ឆស័ក ច.ស.១៣៧៦
ត្រូវនឹងថ្ងៃទី ២៩ ខែ វិច្ឆិកា ព.ស.២៥៥៨ ។
ធម្មានន្ទ ទ៊ាន់ ចាន់សារ៉ែន

ការថ្វាយបង្គំ ៣ យ៉ាង

(គម្ពីរបរមត្ថទីបនី សង្គ្ហមហាដីកា និងនមក្ការដីកា)

ការថ្វាយបង្គំមាន ៣ យ៉ាង ដោយចំណែកក្នុងការថ្វាយបង្គំផ្លូវកាយ ជាដើម សម ដូចព្រះពុទ្ធវចនៈថា ៖

តិសេ្ឋ ១មា ភិក្ខវេ វន្ទនា ។ កតមា តិសេ្ឋ ? កាយេន វន្ទតិ, វាចាយ វន្ទតិ, មនសា វន្ទតិ ។

ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំមាន ៣ យ៉ាង ។ ៣ យ៉ាងនោះ តើដូចម្តេច ? ការថ្វាយបង្គំដោយកាយ ១ ដោយវាចា ១ ដោយចិត្ត ១ ។

បុគ្គលណាមានចិត្តដ៏ប្រសើរឲ្យតាំងនៅចំពោះមុខ ហើយញ៉ាំងអវយវៈ ទាំង ៥ គឺ ជើង ២ ដៃ ២ ក្បាល ១ ឲ្យតាំងនៅត្រង់ផ្ទៃ ក្រាបចុះចំពោះមុខ អ្នកដែលគួរដល់ការ ថ្វាយបង្គំ ហៅថា **ថ្វាយបង្គំដោយកាយ** *។*

អ្នកពោលស្វាធ្យាយសម្តែងគុណសម្បត្តិដោយវាចាហៅថា **ថ្វាយបង្គំដោយវាចា** *ដូចពោលថា* **នមោ ពុទ្ធ្ធស្ស, នមត្ថុ ពុទ្ធ្ធស្ស, នមោ វិមុត្តិយា, នមោ វិមុត្តានំ, វិបស្សិស្ស នមត្ថុ** *ជាដើម ចាត់ជាការ* **ថ្វាយបង្គំដោយវាចា** *។*

ចំណែកការរលឹកដល់គុណសម្បត្តិស្មើ ដោយបណ្តាយតាមពាក្យសម្តែងគុណសម្បត្តិ ហៅថា **ថ្វាយបង្គំដោយចិត្ត** *។*

បទបាលី ឬគាថាទាំងនេះ ជាបទគាថាដែលគួរដល់កិរិយានមស្ការថ្វាយបង្គំ ចម្រើនឥ ពុទ្ធានុស្សតិ រលឹកដល់គុណនៃព្រះពុទ្ធ, ធម្មានុស្សតិ រលឹកដល់គុណនៃព្រះធម៌, សង្ឆានុស្សតិ រលឹកដល់គុណនៃព្រះសង្ឆ នាំឲ្យយើងបានសម្រេចនូវបុណ្យកុសលរាប់ប្រមាណមិនបាន នឹង បានជាបច្ច័យនាំឲ្យសម្រេចនូវសេចក្តីសុខទាំងបច្ចុប្បន្ន និងបរលោក ជាពិសេសជាបច្ច័យនាំឲ្យ បានដល់ទីដ៏ក្សេមពោល គឺព្រះនិព្វានហោង ។

អនុមោទនា ភាវនាចម្រើនព្រះពុទ្ធគុណ ព្រះធម្មគុណ និងព្រះសង្ឆគុណ !

មាតិកាអត្ថបទ

មាតិកា	**ទំព័រ**
បទសរភញ្ញ	១
បូជាព្រះរតនត្រ័យ(សីសំ មេ បទុមំ ភគ្ឆ)	២
រតនត្តយបូជា (ឥមេហិ ទីបធូបា)	២
នមស្ការ បទបឋាវត្ត (នមោ ៨ បទ)	៣
នមោ ៣ បទ	៣
នមោ ៣ បទ រួបរួមជា ១ បទ	៤
នមស្ការចំពោះព្រះពុទ្ធជាមហានាគ	៤
នមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ	៥
ពុទ្ធរតនឋ្យណាម	៨
ធម្មរតនឋ្យណាម	១១
សង្ឆ្យរតនឋ្យណាម	១៣
ជារមីទាំង ៣០	១៨
នមស្ការព្រះពុទ្ធ ៧ ព្រះអង្គ	២២
នមស្ការព្រះពុទ្ធ ២៨ ព្រះអង្គ	២៤
ព្រះពុទ្ធគុណ ៧ អង្គ (វិបស្សី ពុទ្ធោ...)	២៥
នមស្ការព្រះពុទ្ធនាមកៃសជ្យគុរុ	២៧
ជារណបរិត្ត	២៨
គាថាជិនបញ្ជរ	៣១
មន្តកំពែងព្រះរតនត្រ័យ	៣៥
គាថាមហាទិព្ធមន្ត	៣៦
មន្តការពារទាំង ៨ ទិស	៣៦
ជាតុចេតិយនមក្ការគាថា	៣៧
អាការវត្ថា (ធម៌អាការវតា)	៣៩
កំពូលកណ្ឌព្រះត្រៃបិដក	៥១
អសីតិមហាសាវ៏ក (ធម៌នមស្ការមហាសាវ៏ក ៨០ អង្ក)	៧០

ជីវទានបាឋ: (ធម៌ជីវទាន) ៧២
មហាមេត្តាបាឋ (ធម៌មហាមេត្រី) ៨៣
មេត្តាសូត្រ (អានិសង្សផ្សាយមេត្តា) ៩២
ឧដ្ឋានសូត្រ (ធម៌អ្នកចូរក្រោកឡើង) ៩៦
សរណាទីបិកាគាថា (ធម៌សម្តែងអំពីទីពឹងដ៏ប្រសើរ) ៩៨
ទលិទ្ទសុត្តគាថា (ធម៌សម្តែងអំពីការមិនក្រ) ៩៩
គារវសុត្តគាថា (ធម៌សម្តែងអំពីការគោរពព្រះសទ្ធម្ម) ១០០
បញ្ញាគោបមសុត្តគាថា (ធម៌ឧបមានឹងកូនកាត) ១០១
សំវេជនីយគាថា (ន គាមធម្មោ ជាដើម) ១០៣
សេចក្ដីដាស់តឿនរបស់ព្រះពុទ្ធបរមគ្រូ ១០៧
មន្ដគាថាសេកទឹកមន្ដ ១១១

បទសរភញ្ញ

សូមថ្វាយបង្គំ-ព្រះសម្ពុទ្ធ ប្រសើរបំផុត-ក្នុងលោកា
ជាគ្រូនៃមនុស្ស-និងទេវតា ទ្រង់ត្រាស់ទេសនា-ប្រដៅសត្ត
ចង្អុលឲ្យដើរ-ផ្លូវកណ្តាល មាគ្គ៑ត្រកាល-អាចកម្ចាត់
ទុក្ខកាយចង្រៃ-ឲ្យខ្ចាយបាត់ អាចកាត់សង្សា-រៈទុក្ខបាន ។
សាសនាព្រះអង្គ-នៅសព្វថ្ងៃ សត្វមានទិស្សរ៉ាយ-ពីបូរាណ
ប្រឹងរៀនប្រឹងស្តាប់-ចេះចាំបាន កាន់តាមលំអាន-បានក្តីសុខ
ឥតមានសុខណា-ស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខ-ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ-តទៅមុខ ក្តីសុខនឹងមាន-ព្រោះធម៑ស្ងប់ ។
ខ្ញុំសូមបង្គំ-ឆ្ពោះព្រះធម៑ ព្រះសង្ឆបវរ-ទាំងគ្រប់សព្ព
រួមជាត្រៃរត្ន-គួរគោរព ជាម្ចប់ត្រជាក់-នៃលោកា
ព្រះរូបព្រះធាតុ-នៃព្រះពុទ្ធ វិសុទ្ធតាងអង្គ-ព្រះសាស្តា
សូមគុណត្រៃរត្ន-ជួយខ្ញុំមក ឲ្យបានសុខា-តរៀងទៅ ។

បូជាព្រះរតនត្រ័យ

សីសំ មេ បទុមំ ភត្វា ទីបញ្ច នយនទ្វយំ

វចសា ធូបការេន មនសា ច សុគន្ធិកំ ១

ខ្ញុំសូមនិនសិរសា ទុកជាផ្ការីកឧត្តម
និងភ្នែកទាំងពីរផ្សំ ទុកជាគ្រឿងប្រទីបភ្លើ ។
ព្រមទាំងសុវាចា ខ្ញុំធ្វើជាធូបប្រពៃ
ចិត្តនឹកព្រះរតនត្រ័យ ទុកជាក្លិនក្រអូបហោង ។

រតនត្តយបូជា

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឆ្ញ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ប្រែថា ខ្ញុំព្រះគុណាសូមបូជាចំពោះនូវព្រះ {ពុទ្ធ / ធម៌ / សង្ឆ} ជាម្ចាស់ដោយគ្រឿងសក្ការៈ ទាំងឡាយមានទៀន និងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះគុណាផង អស់កាលជាអង្វែងទៅហោង ។

នមស្ការ បទបញ្ជាវត្ត

នមោ ៨ បទ

នមោ អរហតោ សម្ម- **សម្ពុទ្ធស្ស មហេសិនោ**
សូមថ្វាយបង្គំព្រោះព្រះអរហន្ត *សម្ពុទ្ធកគន្ធកាលស្វែកវកធម៌*
គឺពោធិញ្ញាណប្រសើរបវរ *បានត្រាស់ដឹងធម៌ដោយអរិយមគ្គ ។*
នមោ ឧត្តមធម្មស្ស **ស្វាក្ខាតស្សេវ តេនិធ**
សូមថ្វាយបង្គំព្រះធម៌ឧត្តម *ដែលព្រះបរមសម្ពុទ្ធសម្តែង*
ដោយប្រពៃពិតប្រាកដជាក់ស្តែង *ព្រះធម៌នោះឯងទុកក្នុងសាសនា ។*
នមោ មហាសង្ឆស្សាបិ **វិសុទ្ធសីលទិដ្ឋិនោ**
សូមថ្វាយបង្គំព្រះសង្ឆប្រសើរ *ដែលលោកបានធ្វើទិដ្ឋិនិងសីល*
ឲ្យបានបរិសុទ្ធផុតចាកមន្ទិល *គឺទិដ្ឋិសីលលោកស្អាតអស់ហើយ ។*
នមោ ឱមាតាឯ្ឋស្ស **រតនត្តយស្ស សាធុកំ**
សូមថ្វាយបង្គំប្រជុំត្រៃត្ន *ប្រារព្ធដោយបទមានបីប្រការ*
ព្រះពុទ្ធព្រះធម៌ព្រះសង្ឆឈ្នះមារ *ប្រសើរអស្ចារ្យប្ញ៏ងប្ញ៏ងពុំបាន ។*
នមោ ឱមកាតីតស្ស **តស្ស ឥត្ថុត្តយស្សបិ**
សូមថ្វាយបង្គំកុំវត្ថុបី *ពិសេសពិសីប្រសើរប្ញ៏ងប្ញ៏ងបានៗ*
ព្រះពុទ្ធព្រះធម៌ព្រះសង្ឆសព្ទហាន *ថយឬកល្យាណដោយគុណគួរគាប់ ។*
នមោការប្ឬតាវេន **ទ្វិតច្ចន្ត ឧបន្ធ្ធ**
សូមថ្វាយបង្គំត្រៃត្នៈ*សោកា* *ឧបទ្រពនានាចូរវិនាសបាត់*
ដោយអានុភាពបុណ្យជួយកម្ចាត់ *ធ្វើក្តីវិបត្តិឲ្យស្ងាត់សូន្យទៅ ។*
នមោការានុតាវេន **សុវត្ថិ ហោតុ សព្ធ្ធ**
សូមថ្វាយបង្គំត្រៃត្នៈ*ទាំងបី* *សូមសុខសួស្ដីកើតសព្ទវេលា*
ដោយអានុភាពធ្វើការវន្ទ *គោរពបូជាព្ធ*ោ*ះ*ព្រ*ះ*ត្រ*ៃ*ត្ន ។*
នមោការស្ស តេជេន **ទ្ធ*ិ*ធ*ិ*ម*ិ*ហ*ោ*ម*ិ* **ត*េ*ជ*ា** ។**
សូមថ្វាយបង្គំត្រៃត្នៈ*សោកា* *តេជៈ*ចេ*ស្ដ*ាសូ*ម*ម*ានជ*ល*ខ*ុ*ំ*
កុ*ន*ង*ពិ*ធ*ីធ*្ម*ើ*ក*ិ*ច*្ច*ថ*្ម*ាយ*ប*ង*្ក*ំ* *តេ*ជ*ៈ*ប*ុ*ណ*្ម*ធ*ំ*ស*ូ*ម*ក*ើ*ត*ម*ាន*ឡ*ើ*ង ។*

នមោ ៣ បទ

នមោ តស្សារ*ហ*ន្ត*ស*្ស **ត*ត*ាវ*ន*្ត*ស*្ស** **ត*ា*ទ*ិ*ន*ោ***
ស*ម*្ម*ា **ស*ា*ម*ំ*ព** **ព*ុ*ទ*្ធ*ស*្ស** **ធ*ម*្ម*ោ** **ទ*ិ*ត*ជ*ា*ទ*ិ*ន*ោ**។**
*សូ*ម*ថ*្ម*ាយ*ប*ង*្ក*ំ*ព*្ធ*ោ*ះ*ព*្រ*ះ*អ*រ*ហ*ន*្ត* *ទ*្ធ*ង*់*ព*្រ*ះ*ន*ា*ម*ត*គ*ន*្ធ*ប*្រ*ស*ើ*រ*ប*វ*រ*

ព្រះអង្គមិនមានព្រះទ័យញាប់ញ័រ ដោយលោកធម៌ទាំង ៨ ឡើយ
ទ្រង់ត្រាស់ដឹងធម៌ដោយប្រពៃហើយ ចែកធម៌នោះឲ្យដល់សត្វទាំងពួង ។

នមោ តស្សេវ ធម្មស្ស និយ្យានិកស្ស ឥដ្ឋតោ
បតេន នវវិធស្ស ស្វាក្ខាតស្សេវ សច្ចតោ ។

សូមថ្វាយបង្គំនូវគុណព្រះធម៌ ស្រង់សត្វនិការចេញចាកសង្សារ
ជាធម៌មានភេទ ៩ ប្រការ ដែលសាស្តាចារ្យពោលទុកទូន្មាន
មានព្រះសោតានោះជាប្រធាន មានព្រះនិញ្ជនជាបរិយោសាន ។

នមោ អរិយសង្ឆស្ស សញ្ជិតូតស្ស សត្ថុនោ
កិលេសានុសយេ សព្ពេ បហានប្បដិបត្តិយា ។

សូមថ្វាយបង្គំនូវគុណព្រះសង្ឆ ប្រសើរគ្រប់អង្គ ជាសិស្សសាស្តា
ជាសង្ឆប្រតិបត្តិលះកាត់តណ្ហា ព្រះទ័យជ្រះថ្លា គ្មានសៅហ្មងឡើយ
អនុសយកិលេសលោកលះអស់ហើយ និងធ្វងជល់ត្រើយ គឺព្រះនិញ្ជន ។

នមោ ៣ បទ រួមជា ១ បទ

នមេ ពុទ្ធំ តិលោកគ្គំ ញ្ញេយ្យសាគរបារគុំ
ភវាភវករំ ធម្មំ គណញ្ច គុណសាគរំ ។

សូមថ្វាយបង្គំនូវព្រះសម្ពុទ្ធ ប្រសើរខ្ពស់ផុតសត្វក្នុងលោក
ព្រះអង្គមានញាណជ្រាលជ្រៅប្រាជ្ញព្រោក ហើយព្រះទ្រង់ជោគជល់ត្រើយសាគរ ។
សូមថ្វាយបង្គំព្រះធម៌ប្រវរ ញ្ជាំងសត្វនិការឲ្យធ្លងចាកកព
សូមថ្វាយបង្គំព្រះសង្ឆជាម្ចាស់ គុណគួរគោរពដូចសាគរធំ
តេជានុភាពផលថ្វាយបង្គំ សូមឲ្យយើងខ្ញុំបានសុខសព្វកាល ។

នមស្ការចំពោះព្រះពុទ្ធជាមហានាគ

សេដ្ឋោ តថាគតោ លោកេ ពុទ្ធនាគោតិ ឥស្សុតោ
នាគេន ទេសិតោ ធម្មោ និយ្យានិកោតិ សញ្ញតោ
តស្សាបិ សាវកោ សង្ឆោ សន្តិន្ទ្រិយោ អនាសវោ
នាការ ចាបកំ អត្ថុ តស្ម នាគោតិ ឥច្ឆរេ ។

ព្រះតថាគតវិសុទ្ធក្នុងលោក ព្រះអង្គមានជោគលើសលោកទាំង ៣
ព្រះនាមពុទ្ធនាគជាពាក្យបាលី អស់ជនប្រុសស្រីគប្បីដឹងច្បាស់ ។
ថាជាព្រះនាមព្រះពុទ្ធជាម្ចាស់ ប្រសើរពេកណាស់លើសមនុស្សទេពតា
ព្រះធម៌ដែលព្រះពុទ្ធនាគទេសនា ប្រោសអស់ទេវតាមនុស្សទាំងឡាយ

ជាធម៌ស្រង់សត្វឲ្យផុតអបាយ   អ្នកប្រាជ្ញទាំងឡាយលោកបានជ្រាបច្បាស់
ព្រះអរិយសង្ឃសាវ័កច្រើនណាស់   ជាសង្ឃនៃព្រះពុទ្ធនាគជាធំ ។
សង្រួមឥន្ទ្រិយស្រគត់ស្រគំ   កិលេសតូចធំក្សិណក្ស័យអស់ហើយ
លោកឈប់ស្រឡះគ្មានប៉ះពាល់ឡើយ   ព្រះសង្ឃនេះហើយដែលទ្រង់ប្រទាន ។
នាមថានាគោទុកជាប្រធាន   ព្រោះលោកពុំមានធម៌ដ៏លាមក
លោកឈប់ស្រឡះលែងធ្វើអាក្រក់   ព្រះលោកនាយកព្រះពុទ្ធនាគនោះ ។
ទ្រង់ប្រោសប្រទាននាគោជាឈ្មោះ   ជាពាក្យពីរោះចំពោះពុទ្ធដីកា
ដោយមានគម្ពីរព្រះមុនីទេសនា   ប្រារព្ធនិងកាឡុទាយីនោះ ។

វន្ទេហំ ពុទ្ធនាគញ្ច   ធម្មំ នាគេន ទេសិតំ
នាគស្សារិយសង្ឃញ្ច   មហានាគន្តិ វិស្សុតំ
ពុទ្ធនាគាទិតេជេន   ឧប្បន្នា ចេ ឧបទ្ទវា
រោគា ចេវន្តរាយា ច   វិនស្សន្តុ អសេសតា ។

យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំ   ចំពោះព្រះបរមពុទ្ធនាគផង
ចំពោះព្រះធម៌ប្រសើរកន្លង   ដែលព្រះច្បាស់ច្បងពុទ្ធនាគសម្ដែង ។
និងព្រះអរិយសង្ឃព្រមទាំងគម្ដែង   មាននាមជាក់ស្ដែងហៅមហានាគោ
ជាទីសាវ័កមានថ្នាក់សេដ្ឋោ   ព្រះពុទ្ធនាគោប្រទានទុកមក ។
តេជះរតនត្រៃថ្លាថ្លៃពន្លក   យើងខ្ញុំសូមជ្រកក្រោមម្លប់សាខា
មានព្រះពុទ្ធនាគជាដើមថ្លៃថ្លា   ទោះរោគភយាឧបទ្រព្យអន្តរាយ
ដែលកើតមានឡើងឲ្យប៉ើងខ្ចាត់ខ្ចាយ   សូមឲ្យរលាយវិនាសបាត់ទៅ
បើពុំទាន់មានឲ្យខាននៅក្រៅ   ចៀសចេញឆ្ងាយទៅកុំនៅរៀងអាយ ។
សូមសុខសព្វកាលត្រអាលសប្បាយ   សម្បត្តិទាំងឡាយសម្បូរណ៍ឥតខ្វះ

នមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ

វន្ទេ តណ្ហង្ករំ ពុទ្ធំ   វន្ទេ មេធង្ករំ មុនឹ
សរណង្ករំ មុនឹ វន្ទេ   ទីបង្ករំ ជិនំ នមេ ។
វន្ទេ កោណ្ឌញ្ញសត្ថារំ   វន្ទេ មង្គលនាយកំ
វន្ទេ សុមនសម្ពុទ្ធំ   វន្ទេ រេវតនាយកំ ។
វន្ទេ សោភិតសម្ពុទ្ធំ   អនោមទស្សឹ មុនឹ នមេ
វន្ទេ បទុមសម្ពុទ្ធំ   វន្ទេ នារទនាយកំ ។
បទុមុត្តរំ មុនឹ វន្ទេ   វន្ទេ សុមេធនាយកំ
វន្ទេ សុជាតសម្ពុទ្ធំ   បិយទស្សឹ មុនឹ នមេ។

អត្ថទស្សី មុនី វន្ទេ ធម្មទស្សី ជិនំ នមេ
វន្ទេ សិទ្ធត្ថសត្ថារំ វន្ទេ តិស្សមហាមុនី។
វន្ទេ បុស្សមហាវីរំ វន្ទេ វិបស្សិនាយកំ
សិខី មហាមុនី វន្ទេ វន្ទេ វេស្សភូនាយកំ ។
កកុសន្ធំ មុនី វន្ទេ វន្ទេ កោណាគមនំ ជិនំ
កស្សបំ សុគតំ វន្ទេ វន្ទេ គោតមនាយកំ ។
អដ្ឋវីសិតិមេ ពុទ្ធា និញ្ចនាមតនាយកា
នមេ តេ សិរសា និច្ចំ តេ មំ រក្ខន្តុ សព្វទា ។

ខ្ញុំសូមបង្គំព្រះបរមសម្ពុទ្ធ មានទ្រាមប្រាកដព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំព្រះបរមបវរ ព្រះមេធង្ករជាសម្ពុទ្ធា ។
សូមក្រាបបង្គំប្រណម្យវន្ទា នូវព្រះកគ្យាព្រះសរណង្ករ
សូមថ្វាយបង្គំព្រះទីបង្ករ មានញ្ញាណបវរបារមីពោរពេញ ។
សូមថ្វាយបង្គំនូវព្រះកោណ្ឌញ្ញ ព្រះអង្គបំពេញធម៌ជាកុសល
ខ្ញុំសូមបង្គំនូវព្រះទសពល ព្រះនាមមង្គលជាសម្ពុទ្ធ: ។
ខ្ញុំសូមបង្គំប្រណម្យគារវ: ព្រះនាមសុមន:សម្ចាសម្ពុទ្ធ
ខ្ញុំសូមបង្គំព្រះបរមសុគត ព្រះនាមប្រាកដព្រះរេវត: ។
ខ្ញុំសូមបង្គំព្រះបរមពុទ្ធ: មានញ្ញាណសោភ: ព្រះនាមសោភិត
ខ្ញុំសូមបង្គំប្រណម្យប្រណីត ឆ្ពោះព្រះវិជិតអនោមទស្សី ។
ខ្ញុំសូមក្រាបថ្វាយវិនកាយសិរសីចំពោះព្រះមុនីព្រះនាមបទុម
ខ្ញុំសូមវិនកាយថ្វាត់ថ្វាយបង្គំ ចំពោះព្រះបរមព្រះនាមនារទ: ។
សូមថ្វាយបង្គំព្រះបរមបទុមុត្តរ: មានញ្ញាណសោភ:រ:ពទ
ខ្ញុំសូមបង្គំនូវព្រះកគ្យា ទ្រង់ព្រះនាមាសុមេធសម្ពុទ្ធ ។
ខ្ញុំសូមបង្គំប្រណម្យក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធព្រះនាមសុជាត
ខ្ញុំសូមបង្គំប្រណម្យអភិវាទ ឆ្ពោះព្រះមុនីនាថបិយទស្សី ។
ខ្ញុំសូមបង្គំឆ្ពោះព្រះជិនស្រី អត្ថទស្សីបារមីខ្ពង់ខ្ពស់
ខ្ញុំសូមបង្គំឆ្ពោះព្រះទ្រង់យស ព្រះនាមចំពោះធម្មទស្សី ។
ខ្ញុំសូមបង្ហោនលំទោនសិរសី បង្គំជិនស្រីព្រះនាមសិទ្ធត្ថ
ខ្ញុំសូមបង្គំនូវព្រះមុនីរតន៍ ព្រះនាមប្រាកដតិស្សសាស្តា ។
ខ្ញុំសូមបង្គំនូវព្រះសម្ចា- សម្ពុទ្ធនាមថាបុស្សមុនី

ខ្ញុំសូមបង្គំប្រណម្យអញ្ជលី ឆ្ពោះព្រះមុនីព្រះនាមវិបស្សី ។
សូមថ្វាយបង្គំបរមជិនស្រី ព្រះនាមសិខីសពេជ្ជពុទ្ធា
ខ្ញុំសូមនិនកាយក្រាបថ្វាយវន្ទា ឆ្ពោះព្រះកគវាព្រះនាមវេស្សភូ ។
សូមបង្គំលើកហត្ថទាំងគូ ឆ្ពោះព្រះជាគ្រូនាមកកុសន្ធ:
ខ្ញុំសូមបង្គំប្រណម្យគារវ: ឆ្ពោះព្រះពុទ្ធ:កោណាគមនោ ។
ខ្ញុំសូមនិនកាយវាចាទន់ទោរ បង្គំពុទ្ធោព្រះនាមកស្សប:
ខ្ញុំសូមលន់ទោរបង្ហើនសិរ: ជាទីគារវ:ព្រះនាមគោតម ។
គម្រប់ម្ភៃប្រាំបីព្រះបរម- សម្ពុទ្ធជាធំកំពូលលោកា
ទូទាំងត្រៃភពជាម្ចប់សាខា មនុស្សសត្វទេវតាមារព្រហ្មទាំងឡាយ ។
ដែលបានចូលជ្រកក្រោមម្ចប់ព្រះឆាយ បានសុខសប្បាយគ្រប់រូបរាល់គ្នា
បានទៅសោយសុខក្នុងឋានសួគ៌ា ឬឋានព្រហ្មនិងព្រះនិញ្ជាន ។
ដោយបុណ្យបារមីនៃព្រះទ្រង់ញាណ ព្រះធម៌ប្រធានជាយានទាំសត្ត
ត្រេជះយើងខ្ញុំប្រណម្យថ្វាយថ្វាត់ ទ្ធវ ព្រះពុទ្ធ្ធ្ធ្ធ្ធ
ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឆ សាវ៉ាកគ្រប់អង្គម្ភៃប្រាំបី
ខ្ញុំសូមអានុភាពពីព្រះជិនស្រី ម្ភៃប្រាំបីព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ព្រះអង្គសម្ដែង ទាំងព្រះគម្ដែងសង្ឆជាសាវ៉ាក
សូមសុខចម្រើនកើតឡើងតាមថ្នាក់ កុំឲ្យមានអាក់រាងរាល់ជាតា ។
សូមឲ្យខ្ញុំបានដល់ឋានទេវតា ដូចក្ដីប្រាថ្នាកុំបីយ្ជៀងឃ្ជាត
មានព្រះនិញ្ជានជាអវសានជាតិ កុំឲ្យខ្ញុំឃ្ជាតពីព្រះនិញ្ជានហោង ។

ពុទ្ធរតនប្បណាម

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(សូត្រ ៣ ដង)

ប្រែថា *រីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគ អង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយ ប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

(ក្រាបថ្វាយបង្គំម្តង)

យោ សន្ធិសិន្ធោ វរពោធិមូលេ
មារំ សសេនំ មហតី វិជេយ្យា
សម្ពោធិមាគច្ឆិ អនន្តញ្ញាណោ
លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។

ប្រែថា *ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានសតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្ស ដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គ នោះដោយគោរព ។*

(ក្រាបថ្វាយបង្គំម្តង)

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។

ប្រែថា *ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វាន កន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែល នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធ ទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងកន្លែងនេះក្តី*

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ
នោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ប្រែថា **ឥតិបិ សោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា* ***អរហំ*** *ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺកិលេសព្រមទាំងវាសនា គឺកាយ-បយោគ និងវចីបយោគ* **សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា* ***សម្មាសម្ពុទ្ធ*** *ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ* **វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា* ***វិជ្ជាចរណសម្បន្នោ*** *ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥* **សុគតោ** *ទ្រង់ព្រះនាម ថា* ***សុគតោ*** *ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុទ្ធស្ថាន គឺអមតមហានិព្វាន* **លោកវិទូ** *ទ្រង់ព្រះនាមថា* ***លោកវិទូ*** *ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក* **អនុត្តរោ** *ទ្រង់ព្រះនាមថា* ***អនុត្តរោ*** *ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន* **បុរិសទម្មសារថិ** *ទ្រង់ព្រះនាមថា* ***បុរិសទម្មសារថិ*** *ព្រោះព្រះអង្គជាអ្នកទូន្មានទូវបុរសដែលមានឧបនិស្សយគួរនឹងទូន្មានបាន* **សត្ថា ទេវមនុស្សានំ** *ទ្រង់ព្រះនាមថា* ***សត្ថា ទេវមនុស្សានំ*** *ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ* **ពុទ្ធោ** *ទ្រង់ព្រះនាមថា* ***ពុទ្ធោ*** *ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច*

ហើយ ញ្ជាំងអ្នកដទៃឲ្យគ្រាស់ដ៏ផង **ភគវា** *ទ្រង់ព្រះនាមថា* **ភគវា** *ព្រោះព្រះអង្គ មានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។*

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវប្រកាសបេជ្ជាខ្ជួនចំពោះព្រះពុទ្ធគុណថា៖

ឧត្តិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ រវំ

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។

ប្រែថា **ឧត្តិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីរឫកនៃខ្ញុំព្រះករុណា មិនមានឡើយ* **ពុទ្ធោ មេ សរណំ រវំ** *មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរឫកដ៏ប្រសើរបស់ខ្ញុំព្រះករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវសូមខមាទោសនឹងព្រះពុទ្ធគុណដូច្នេះថា៖

ឧត្តមង្គេន វន្ទេហំ ចាឧបំសុំ រុត្តមំ

ពុទ្ធេ យោ ១លិតោ ទោសោ ពុទ្ធោ ១មតុ តំ មមំ ។

ប្រែថា **ឧត្តមង្គេន វន្ទេហំ ចាឧបំសុំ រុត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អង់ធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយៈដ៏ឧត្តមគឺត្បូង* **ពុទ្ធេ យោ ១លិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យក្ងាំងក្ងាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់* **ពុទ្ធោ ១មតុ តំ មមំ** *សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។*

(ក្រាបថ្វាយបង្គំម្តង)

ធម្មរតនប្បណាម

អដ្ឋង្គិការិយបថោ ៨ឋានំ

មោក្ខប្ប្ជវេសាយ ឧជូ ច មគ្គោ

ធម្មោ អយំ សន្តិករោ បណីតោ

នេយ្យានិកោ តំ បនមាមិ ធម្មំ ។

ប្រែថា ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្ធង៨ដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយា ញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឲ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា

បច្ចុប្ប្ជន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្ធងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ ព្រះសម្មាសម្ពុទ្ធដែលនឹងមាន មកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយ ឯណាដែលជាធម៌របស់ ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយ នោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

គួរបង្ហាញកាយវាចា ហើយតាំងចិត្តរាប្រកដល់ព្រះធម្មគុណថា៖

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្ពោ វិញ្ញូហីតិ។

ប្រែថា **ស្វាក្ខាតោ ភគវតា ធម្មោ** *ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ* **ធម្មោ** *ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១* **សន្ទិដ្ឋិកោ** *ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង* **អកាលិកោ** *ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ* **ឯហិបស្សិកោ** *ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន* **ឱបនយិកោ** *ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃការនា* **បច្ចត្តំ វេទិតព្ពោ វិញ្ញូហិ** *ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយមានខគ្ឃជិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។*

(ក្រាបថ្វាយបង្គំម្តង)

ប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា៖

ឧត្តិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។

ប្រែថា **ឧត្តិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ* **ធម្មោ មេ សរណំ វរំ** *មានតែព្រះធម៌ជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើរ*

របស់ខ្ញុំ ព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តី ជយមង្គលចូរមាន ដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវសូមខមាទោសនឹងព្រះធម្មគុណថា៖

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ

ធម្មេ យោ ១លិតោ ទោសោ ធម្មោ ១មតុ តំ មមំ ។

ប្រែថា **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយៈដ៏ឧត្តម គឺក្បាល* **ធម្មេ យោ ១លិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យក្វាំងក្វាត់ហើយក្នុងព្រះធម៌ជាម្ចាស់* **ធម្មោ ១មតុ តំ មមំ** *សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

(ក្រាបថ្វាយបង្គំម្តង)

សង្ឆរតនប្បណាម

សង្ឆោ វិសុទ្ធោ វរទក្ខិណេយ្យោ

សន្តិន្ទ្រិយោ សព្វមលប្បហីនោ

គុណេហិ នេកេហិ សមិទ្ធិបត្តោ

អនាសវោ តំ បណមាមិ សង្ឆំ ។

ប្រែថា ព្រះអរិយសង្ឆឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្លិសេសទាំងពួងបន្ទាត់បង់ហើយ ជាព្រះសង្ឆដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឆមានអាសវធម៌មិនមាន គឺថា

ជាព្រះវ៉ីណាស្រេព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឆ នោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

យេ ច សង្ឆា អតីតា ច យេ ច សង្ឆា អនាគតា

បច្ចុប្បន្នា ច យេ សង្ឆា អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះសង្ឆទាំងឡាយឯណា ដែលជាព្រះសង្ឆបានសម្រេចមគ្ គ និងផលកន្ទងទៅហើយក្តី ព្រះសង្ឆទាំងឡាយឯណា ដែលជាព្រះសង្ឆ នឹងបានសម្រេចមគ្ គ និងផលក្នុងកាលខាងមុខក្តី ព្រះសង្ឆទាំងឡាយឯណា ដែលជាព្រះសង្ឆបានសម្រេចមគ្ គ និងផលក្នុងកាលជាបច្ចុប្បន្ន នេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឆទាំងឡាយនោះ គ្រប់កាលទាំងពួង។

(ក្រាបថ្វាយបង្គំម្តង)

រួចហើយគប្បីតាំងចិត្តរព្ធកជល់ព្រះសង្ឆគុណដោយបន្ទោនកាយវាចាថា៖

សុបដិបន្ធោ ភគវតោ សាវកសង្ឆោ

ឧជុបដិបន្ធោ ភគវតោ សាវកសង្ឆោ

ញាយបដិបន្ធោ ភគវតោ សាវកសង្ឆោ

សាមីចិបដិបន្ធោ ភគវតោ សាវកសង្ឆោ

យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឆោ អាហុនេយ្យោ ចាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ-ករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស្ជាតិ ។

ប្រែว่า **សុបដិបន្នោ ภควาโต สาวกสงฺโฆ** ព្រះសង្ឆជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្ធង៨ព្រះនព្វ-លោកុត្តរធម៌

ឧជុបដិបន្នោ ภควาโต สาวกสงฺโฆ ព្រះសង្ឆជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា

ญายปฏิปนฺโน ภควาโต สาวกสงฺโฆ ព្រះសង្ឆជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានកន្លែងផុតចាកទុក្ខទាំងពួង

สามีจิปฏิปนฺโน ภควาโต สาวกสงฺโฆ ព្រះសង្ឆជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា

យទิទํ ចตฺตาริ ปุริสยุคานิ ព្រះសង្ឆឯណា បើរាប់ជាគូនៃបុរសទាំងឡាយ មាន ៤ គូ គឺព្រះសង្ឆដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគামិមគ្គ និងសកទាគামិផលជាគូ ១ អនាគামិមគ្គ និងអនាគামិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១

អដฺฐ ปุริสปุคฺคลา បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឆដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគামិមគ្គ ១ សក-ទាគামិផល១ អនាគামិមគ្គ១ អនាគামិផល១ អរហត្តមគ្គ១ អរហត្តផល១

ឯส ภควาโต สาวกสงฺโฆ ព្រះសង្ឆទាំងនុ៎ះ ជាសង្ឆសាវ័ក នៃព្រះដ៏មានព្រះភាគ

អาหุเนยฺโย លោកគួរទទួលនូវចតុប្ប្ជ្ជ័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្ហានចូលមកបូជា

ចាហុនេយ្យោ *លោកគួរទទួលនូវអាគន្ទុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិ និងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្ហោនចូលមកបូជា*

ឧក្ខិណេយ្យោ *លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា*

អញ្ជលិការណីយោ *លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ*

អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស *លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពួជគឺបុណ្យ នៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។*

(ក្រាបថ្វាយបង្គំម្តង)

តទៅគប្បីប្រកាសប្តេជ្ញាខ្ជនចំពោះព្រះសង្ឆគុណថា ៖

ឧត្តិ មេ សរណំ អញ្ញំ សង្ឆោ មេ សរណំ វរំ

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។

<u>ប្រែថា</u> **ឧត្តិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីពួកនៃខ្ញុំព្រះករុណា មិនមានឡើយ*

សង្ឆោ មេ សរណំ វរំ *មានតែព្រះសង្ឆជាម្ចាស់ ជាទីពឹងទីពួកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា*

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ *សូមសិរីសួស្តី ជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

រួចហើយត្រូវសូមវត្ថុនិងព្រះសង្ឆគុណថា ៖

ឧត្តមង្គេន វន្ទេហំ សង្ឆញ្ច ទ្ធុវិធោត្តមំ

សង្ឆ យោ ១លិតោ ទោសោ សង្ឆោ ១ខមតុ តំ មមំ ។

ប្រែว่า **ឧត្តមង្គេន វន្ទេហំ សង្ឆញ្ច ទ្ធុវិធោត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឆដ៏ប្រសើរ មានពីរប្រការ គឺសម្មតិសង្ឆ និងអរិយសង្ឆ ដោយអវយៈដ៏ឧត្តម គឺត្បូង*

សង្ឆេ យោ ១លិតោ ទោសោ *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យក្ងាំងក្ងាត់ហើយក្នុងព្រះសង្ឆជាម្ចាស់*

សង្ឆោ ១មតុ តំ មមំ *សូមព្រះសង្ឆជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។*

(ក្រាបថ្វាយបង្គំម្តង)

ចារមីធាំ ៣០

ឥតិបិ ទានចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គ បរិបូណ៌ហើយដោយទានបារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ ទានឧបចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានឧបបារមី មែនព្រោះហេតុដូច្នេះ។*

ឥតិបិ ទានបរមត្ថចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានបរមត្ថបារមី មែនព្រោះហេតុដូច្នេះ។*

ឥតិបិ សីលចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបារមី មែនព្រោះហេតុដូច្នេះ។*

ឥតិបិ សីលឧបចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលឧបបារមី មែនព្រោះហេតុដូច្នេះ។*

ឥតិបិ សីលបរមត្ថចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ នេក្ខម្មចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ នេក្ខម្មឧបចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មឧបបារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ នេក្ខម្មបរមត្ថចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មាព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ បញ្ញាចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ បញ្ញាឧបចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាឧបចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ បញ្ញាបរមត្ថចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបរមត្ថចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ វីរិយចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គ បរិបូណ៌ហើយ ដោយវីរិយចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ វីរិយឧបចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវីរិយឧបចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ វីរិយបរមត្ថចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវីរិយបរមត្ថចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ ខន្តិចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គ បរិបូណ៌ហើយ ដោយខន្តីចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ ខន្តិឧបចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តីឧបចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ ខន្តិបរមត្ថចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តីបរមត្ថចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ សចុចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសចុចារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ សច្ចឧបចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចឧបចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ សច្ចបរមត្ថចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបរមត្ថចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ អធិដ្ឋានចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ អធិដ្ឋានឧបចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានឧបចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ អធិដ្ឋានបរមត្ថចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគ-អង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបរមត្ថចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ មេត្តាចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ មេត្តាឧបចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាឧបចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ មេត្តាបរមត្ថចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបរមត្ថចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ ឧបេក្ខាចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ ឧបេក្ខាឧបចារមិសម្ផន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាឧបចារមី មែនព្រោះហេតុដូច្នេះ ។

ឥតិបិ ឧបេក្ខាបារមត្តចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបារមត្តបារមី មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ ទសចារមិសម្ផន្នោ ទសឧបចារមិសម្ផន្នោ ទសបារមត្ត-ចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមី១០ បរិបូណ៌ហើយ ដោយឧបបារមី១០ បរិបូណ៌ហើយដោយបារមត្តបារមី១០ មែនព្រោះហេតុដូច្នេះ ។*

ឥតិបិ សមត្តឹសចារមិសម្ផន្នោ សោ ភគវា *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមីទាំង៣០ មែនព្រោះហេតុដូច្នេះ ។*

នមស្ការព្រះពុទ្ធ ៧ ព្រះអង្គ

វិបស្សិស្ស ច នមត្ថុ ចក្ខុមន្តស្ស សិរីមតោ

សិខិស្សបិ ច នមត្ថុ សព្វភូតានុកម្បិនោ។

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តីអនុគ្រោះដល់សត្វទាំងពួងជាប្រក្រតី ។

វេស្សភុស្ស ច នមត្ថុ ឌ្ឌាតកស្ស តបស្សិនោ

នមត្ថុ កកុសន្ធស្ស មារសេនប្បមទ្ទិនោ។

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមវេស្សភូ ព្រះអង្គមានកិលេសលាងស្អាតហើយ ព្រះអង្គមានតបធម៌ សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមកកុសន្ធ: ព្រះអង្គញាំញីនូវមារព្រមទាំងសេនានៃមារ ។

កោណាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ

កស្សបស្ស ច នមត្ថុ វិប្ប មុត្តស្ស សព្វធិ។

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមកោណាគមន: ព្រះអង្គមានបាបបន្សាត់ចោលហើយ មានព្រហ្មចរិយធម៌នៅរួចហើយ សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមកស្សប: ព្រះអង្គផុតចាកកិលេសទាំងពួងហើយ ។

អង្គីរសស្ស នមត្ថុ សក្យបុត្តស្ស សិរីមតោ

យោ ឥមំ ធម្មំ ទេសេសិ សព្វទុក្ខាបនូទនំ។

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាម
អង្គីរស: ព្រះអង្គជាបុត្រនៃសក្យរាជ ដ៏មានសិរី
ព្រះសម្ពុទ្ធអង្គឯណា ទ្រង់បានត្រាស់សម្តែងហើយនូវធម៌នេះ
ជាធម៌បន្ទោបង់នូវទុក្ខទាំងពួង ។

យេ ចាបិ និព្ពុតា លោកេ យថាភូតំ វិបស្សិសុំ
តេ ជនា អបិសុណាថ មហន្តា វីតសារទា។

ម្យ៉ាងទៀត ព្រះសម្ពុទ្ធទាំងឡាយអង្គឯណា ព្រះអង្គ
រំលត់កិលេសហើយក្នុងលោក ទ្រង់ឃើញច្បាស់នូវធម៌តាម
សេចក្តីពិត ព្រះសម្ពុទ្ធទាំងឡាយនោះ ព្រះអង្គមិនមាន
សេចក្តីញុះញង់ស៊ីកសៀត ទ្រង់ប្រសើរដោយព្រះគុណ
មានសេចក្តីក្រវល់ក្រវាយ(ព្រោះកិលេស)ទៅប្រាសហើយ។

ហិតំ ទេវមនុស្សានំ យំ នមស្សន្តិ គោតមំ
វិជ្ជាចរណសម្ផន្នំ មហន្តំ វីតសារទំ។

ទេវតានិងមនុស្សទាំងឡាយ រមែងនមស្លា នូវព្រះសម្ពុទ្ធអង្គ
ឯណាជាគោតមគោត្រ ជាប្រយោជន៍ដល់ទេវតានិងមនុស្ស
ទាំងឡាយ ព្រះអង្គបរិបូណ៌ ដោយវិជ្ជានិងចរណៈប្រសើរ
ដោយព្រះគុណមានសេចក្តីក្រវល់ក្រវាយ(ព្រោះកិលេស)
ទៅប្រាសហើយ ។

នមស្ការព្រះពុទ្ធ ២៨ ព្រះអង្គ

នមោ មេ សព្វពុទ្ធានំ ឧប្ផន្នានំ មហេសិនំ

តណ្ហង្ករោ មហាវីរោ មេធង្ករោ មហាយសោ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ (ព្រះសម្ពុទ្ធ ទាំងនោះ គឺ)ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ ព្រះមេធង្ករ ព្រះអង្គមានយសធំ ។

សរណង្ករោ លោកហិតោ ទីបង្ករោ ជុតិន្ធរោ

កោណ្ឌញ្ញោ ជនចាមោក្ខោ មង្គលោ បុរិសាសភោ។

ព្រះសរណង្ករ ព្រះអង្គធ្វើឲ្យជាប្រយោជន៍ដល់សត្វលោក ព្រះទីបង្ករព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន ព្រះមង្គលៈព្រះអង្គជាបុរសដ៏ប្រសើរ ។

សុមនោ សុមនោ ធីរោ រេវតោ រតិវឌ្ឍនោ

សោភិតោ គុណសម្ផន្នោ អនោមទស្សី ជនុត្តមោ ។

ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ ព្រះរេវតៈ ព្រះអង្គញ្ចាំងសេចក្ដីត្រេកអរឲ្យចម្រើន ព្រះសោភិតៈ ព្រះអង្គបរិបូណ៌ ដោយព្រះគុណ ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន ។

បទុមោ លោកបជ្ជោតោ នារទោ រតិសារថិ

បទុមុត្តរោ សត្ថសារោ សុមេធោ អប្ផដិបុគ្គលោ។

ព្រះបទុមៈ ព្រះអង្គញ្ចាំងលោកឲ្យភ្លឺស្វាង ព្រះនារទៈ ព្រះអង្គជួច ជាសារថីដ៏ប្រសើរ ព្រះបទុមុត្តរៈ ព្រះអង្គជាទ្វីមសារនៃពពួកសត្ត ព្រះសុមេធៈ ព្រះអង្គកបុគ្គលប្រៀបដូចគ្មាន ។

សុជាតោ សព្វលោកគ្គោ　　បិយទស្សី នរាសភោ

អត្ថទស្សី ការុណិកោ　　ធម្មទស្សី តមោនុទោ។

ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង
ព្រះបិយទស្សីព្រះអង្គប្រសើរជាងនរជន ព្រះអត្ថទស្សី ព្រះអង្គ
ប្រកបដោយករុណា ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត ។

សិទ្ធត្ថោ អសមោ លោកេ　　តិស្សោ ច វទតំ វរោ

បុស្សោ ច វរទោ ពុទ្ធោ　　វិបស្សី ច អនូបមោ។

ព្រះសិទ្ធត្ថៈ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក
ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសម្តីទាំងឡាយ
ព្រះពុទ្ធទ្រង់ព្រះនាមបុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ
ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ។

សិខី សព្វហិតោ សត្ថា　　វេស្សភូ សុខទាយកោ

កកុសន្ធោ សត្ថវាហោ　　កោណាគមនោ រណញ្ជហោ

កស្សបោ សិរិសម្បន្នោ　　គោតមោ សក្យបុង្គវោ ។

ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឲ្យជាប្រយោជន៍ដល់សត្វទាំងពួង
ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វ
ចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស ព្រះកោណាគមនៈ ព្រះអង្គបំបាត់បង់
នូវសត្រូវ គឺកិលេស ។ ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី
ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ។

ព្រះពុទ្ធគុណ ៧ អង្គ

១- វិបស្សី ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។ *ព្រះពុទ្ធព្រះនាម **វិបស្សី** ដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យដ៏ច្រើន មានញាណ ដ៏ច្រើន មានគុណដ៏ច្រើន មានតេជៈដ៏ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាព ដ៏ច្រើន ។*

២- សិខី ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។ *ព្រះពុទ្ធព្រះនាម **សិខី** ដ៏មានព្រះភាគ ជា*

ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ ទ្រង់មានបុណ្យជ៏ច្រើន មានញាណជ៏ច្រើន មានគុណជ៏ច្រើន មានតេជៈជ៏ ច្រើន មានឫទ្ធិជ៏ច្រើន មានអានុភាពជ៏ច្រើន ។

៣-វេស្សភូ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញ្ញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។ *ព្រះពុទ្ធព្រះនាម **វេស្សភូ** ជ៏មានព្រះភាគ ជា ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះ អង្គទ្រង់មានបុណ្យជ៏ច្រើន មានញាណជ៏ច្រើន មានគុណជ៏ច្រើន មានតេជៈ ជ៏ច្រើន មានឫទ្ធិជ៏ច្រើន មានអានុភាពជ៏ច្រើន ។*

៤- កកុសន្ធោ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញ្ញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។ *ព្រះពុទ្ធព្រះនាម **កកុសន្ធោ** ជ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យជ៏ច្រើន មានញាណជ៏ច្រើន មានគុណជ៏ច្រើន មាន តេជៈជ៏ច្រើន មានឫទ្ធិជ៏ច្រើន មានអានុភាពជ៏ច្រើន ។*

៥- កោណាគមនោ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញ្ញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។ *ព្រះពុទ្ធព្រះនាម **កោណាគមនោ** ជ៏មានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យជ៏ច្រើន មានញាណជ៏ច្រើន មានគុណជ៏ច្រើន មាន តេជៈជ៏ច្រើន មានឫទ្ធិជ៏ច្រើន មានអានុភាពជ៏ច្រើន ។*

៦- កស្សបោ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញ្ញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។ *ព្រះពុទ្ធព្រះនាម **កស្សបោ** ជ៏មានព្រះភាគ ជា ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យជ៏ច្រើន មានញាណជ៏ច្រើន មានគុណជ៏ច្រើន មាន តេជៈជ៏ច្រើន មានឫទ្ធិជ៏ច្រើន មានអានុភាពជ៏ច្រើន ។*

៧- អម្ហាកំ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញ្ញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។ *ព្រះពុទ្ធជាម្ចាស់នៃយើង ជ៏មានព្រះភាគ ជា ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ ទ្រង់មានបុណ្យជ៏ច្រើន មានញាណជ៏ច្រើន មានគុណជ៏ច្រើន មាន តេជៈជ៏ច្រើន មានឫទ្ធិជ៏ច្រើន មានអានុភាពជ៏ច្រើន ។*

សត្តិមេ ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តបុញ្ញា អនន្តញ្ញាណា អនន្តគុណា អនន្តតេជា អនន្តឥទ្ធិមន្តា អនន្ត-ជុតិមន្តា។ *ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ នោះ ជ៏មានព្រះភាគ ជាព្រះ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យ ជ៏ច្រើន មានញាណជ៏ច្រើន មានគុណជ៏ច្រើន មានតេជៈជ៏ច្រើន មានឫទ្ធិជ៏ច្រើន មានអានុភាពជ៏ច្រើន ។*

មយ្ហំ ទីបា មយ្ហំ នាថា មយ្ហំ បតិដ្ឋា មយ្ហំ តាណា មយ្ហំ លេណា មយ្ហំ បដិសរណា។ *ព្រះពុទ្ធ ទាំងឡាយនោះ ព្រះអង្គជាទីពំង ជាទីអាស្រ័យ ជាទីជ្រកកោន ជាទីពួន ជាទីការពារ ជាទីរលឹកនៃយើងខ្ញុំ ។*

១-អនន្តបុញ្ញា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ បុញ្ញចក្កេហិ មំ រក្ខន្តុ ។ *ព្រះពុទ្ធទាំងឡាយជ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដ៏ែលទ្រង់មានបុណ្យជ៏ច្រើន សូមចក្ក គឺបុណ្យជ៏ច្រើន រក្សា នូវខ្ញុំ ។*

២-អនន្តញ្ញាណា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ ញ្ញាណចក្ខេហិ មំ រក្ខន្តុ ។ *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មានញាណដ៏ច្រើន សូមចក្ខុ គឺញាណដ៏ច្រើន រក្សានូវខ្ញុំ ។*

៣- អនន្តគុណា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ គុណចក្ខេហិ មំ រក្ខន្តុ ។ *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មានគុណដ៏ច្រើន សូមចក្ខុគឺគុណដ៏ច្រើន រក្សានូវខ្ញុំ។*

៤- អនន្តតេជា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ តេជចក្ខេហិ មំ រក្ខន្តុ ។ *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មាន តេជៈដ៏ច្រើន សូមចក្ខុ គឺតេជៈដ៏ច្រើន រក្សានូវខ្ញុំ ។*

៥- អនន្តឥទ្ធិមន្តា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ ឥទ្ធិចក្ខេហិ មំ រក្ខន្តុ ។ *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មាន ឫទ្ធិដ៏ច្រើន សូមចក្ខុ គឺឫទ្ធិដ៏ច្រើន រក្សានូវខ្ញុំ ។*

៦- អនន្តជុតិមន្តា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ ជុតិចក្ខេហិ មំ រក្ខន្តុ ។ *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មាន អានុភាព ដ៏ច្រើន សូមចក្ខុ គឺអានុភាពដ៏ច្រើន រក្សានូវខ្ញុំ ។*

កតា មេ រក្ខា, កតំ មេ បរិត្តំ, បដិក្កមន្តុ ភូតានិ, សោហំ នមោ ភគវតោ, នមោ សត្តន្នំ សម្មាសម្ពុទ្ធានំ *ការិយារក្សា អាត្មាអញបានធ្វើហើយ ទាំងការិយាការ៉ាង អាត្មាអញ ក៏បានធ្វើហើយ ពួកសត្ត (ការ) ទាំងឡាយ ចូរចៀសចេញទៅ អាត្មាអញ (ធ្វើឥឡូវនេះ) នូវការិយានមស្ការ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ (អាត្មាអញធ្វើឥឡូវនេះ) នូវការិយានមស្ការ ចំពោះ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ ។*

នមស្ការព្រះពុទ្ធនាមតែសជ្ឈគ្ករ

នមោ ភគវតេ តែសជ្ឈគ្ករ
ទ្ធៃទ្ធ្យ្ធ្ប្ធ្ករ៉ាជ្ញ ត្ថ្ថ្ធ្ធ
អ៌ហ៌ តេ សម្ម្ធ្ធ្ធ ត្ថ
ឱ្ម ត្ថ្ធ ត្ថ្ធ ម្ហ ត្ថ
សមុ្ធ ត្ថ ស្ហ ។

សូមឲ្យសព្វសត្វបានសម្រេចនូវជោគជ័យ! ខ្ញុំសូមនមស្ការនូវ ព្រះដ៏មានព្រះភាគ ដែលជាតែសជ្ឈគ្ករ ដូចជាស្តេចនៃពន្ធឺតែ ពិទ្ធ្ យ ជាព្រះតថាគតដែលទ្រង់មានដំណើរល្អយ៉ាងទៅកាន់ សុន្ទ្ធ ស្ថាន គឺព្រះនិព្វាន ជាព្រះអរហន្ត ដែលទ្រង់ត្រាស់ដឹងនូវ

សម្មាសម្ពោធិញ្ញាណដោយប្រពៃចំពោះព្រះអង្គឯង
គ្មានគ្រូអាចារ្យណាប្រដៅព្រះអង្គ
ឱម ព្រះអង្គជាគ្រូពេទ្យ ជាគ្រូពេទ្យ ជាកំពូលគ្រូពេទ្យ
ជាស្តេចនៃគ្រូពេទ្យ ។

ធារណបរិត្ត

១.ពុទ្ធានំ ជីវិតស្ស ន សក្កា កេនចិ អន្តរាយោ កាតុំ, តថា មេ ហោតុ, អតីតំសេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ, អនាគតំសេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ, បច្ចុប្បន្នំសេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ ។

រីជីវិតរបស់ព្រះពុទ្ធទាំងឡាយ មិនអាចបុគ្គលណាមួយធ្វើឲ្យអន្តរាយបានឡើយយ៉ាងណា សូមការរស់នៅរបស់ខ្ញុំ ចូរជាយ៉ាងនោះចុះ, រីព្រះញាណដែលមិនមានគ្រឿងរារាំងរបស់ព្រះពុទ្ធអ្នកមានបុណ្យ រមែង មានក្នុង អតីតៈ ក្នុងអនាគត និងបច្ចុប្បន្ន ។

២.ឥមេហិ តីហិ ធម្មេហិ សមន្នាគតស្ស ពុទ្ធស្ស ភគវតោ, សព្វំ កាយកម្មំ ញាណបុព្វង្គមំ ញាណានុបរិវត្តិ, សព្វំ វចីកម្មំ ញាណបុព្វង្គមំ ញាណានុបរិវត្តិ, សព្វំ មនោកម្មំ ញាណបុព្វង្គមំ ញាណានុបរិវត្តិ ។

រីកាយកម្មទាំងពួង របស់ព្រះដ៏មានព្រះភាគដែលជាព្រះពុទ្ធ ប្រកបព្រមដោយគុណធម៌ទាំងនេះ មានញាណជាប្រធាន ប្រព្រឹត្តទៅតាមញាណ រីវចីកម្មទាំងពួងរបស់ព្រះដ៏មានព្រះភាគដែលជាព្រះពុទ្ធ ប្រកបព្រមដោយគុណធម៌ទាំងនេះ មានញាណជាប្រធាន ប្រព្រឹត្តទៅតាមញាណ រីមនោកម្ម ទាំងពួងរបស់ព្រះដ៏មានព្រះភាគដែលជាព្រះពុទ្ធ ប្រកបព្រមដោយគុណធម៌ទាំងនេះ មានញាណជាប្រធាន ប្រព្រឹត្តទៅតាមញាណ ។

៣.ឥមេហិ ឆហិ ធម្មេហិ សមន្នាគតស្ស ពុទ្ធស្ស ភគវតោ, នត្ថិ ឆន្ទស្ស ហានិ, នត្ថិ ធម្មទេសនាយ ហានិ, នត្ថិ វីរិយស្ស ហានិ, នត្ថិ សមាធិស្ស ហានិ, នត្ថិ បញ្ញាយ ហានិ, នត្ថិ វិមុត្តិយា ហានិ ។

រីសេចក្តីវិនាសដោយគុណធម៌ ៦ ប្រការទាំងនេះ រមែងមិនមានដល់ ព្រះដ៏មានព្រះភាគ ដែលជាព្រះពុទ្ធ ដែលព្រះអង្គជាអ្នកដល់ព្រមហើយ ពោលគឺ សេចក្តីវិនាស

ឆន្ទ: វិនាសដោយការសម្តែងព្រះធម៌ វិនាសដោយសេចក្តីព្យាយាម វិនាសដោយសមាធិ វិនាសដោយបញ្ញា និងវិនាសដោយវិមុត្តិញាណ ។

៤.ឥមេហិ ទ្វាទសហិ ធម្មេហិ សមន្នាគតស្ស ពុទ្ធស្ស ភគវតោ, នត្ថិ ទារ, នត្ថិ រារ, នត្ថិ អប្ផុដំ, នត្ថិ វាយាមិតត្តំ, នត្ថិ អព្យាវដមនោ, នត្ថិ អប្បដិសង្ខានុបេក្ខា ។

